# អ្នកតាជិះដំរី

នៅក្នុងក្របខណ្ឌវប្បធម៌ជំនឿ គេចែកចេញជាពីរធំៗគឺ ជំនឿជីវចល និងជំនឿសាសនា។ "ជំនឿជីវចល" គឺជាជំនឿដែលបានផ្សាភ្ជាប់ព្រលឹងទៅនឹងសត្វ បាតុភូតផ្សេងៗ វត្ថុធម្មជាតិ។ ជំនឿជីវចល បង្ហាញក្រោមចក្ខុយើងនូវគំនិតសាសនាមួយដែលជឿថាមានវត្តមាននៃព្រលឹងនៅក្នុងវត្ថុនានា ឬទឹកទន្លេនានាដែលផ្តល់ឲ្យអំណាចដល់ខ្មោច ដើម្បីមានអនុភាពលើមនុស្ស និងផ្តល់ឱ្យមនុស្សខ្លះនូវអំណាចអធិធម្មជាតិ។ ជំនឿជីវចលសម្តែងចេញមកក្នុងជីវភាពសហគមន៍ មជ្ឈដ្ឋានជនបទ តាមរយៈពិធីបុណ្យទៀងទាត់ ការគោរពអ្នកតា ម្ចាស់ទឹកម្ចាស់ដី ម្ចាស់ស្រុក និងអ្វីៗផ្សេងៗទៀតលាយចម្រុះគ្នានៅក្នុងជំនឿស៊ប់ និងការប្រតិបត្តិ។ ជំនឿនេះលាយឡំជាមួយនឹងសាសនាជាប្រចាំ ក្នុងផ្នត់គំនិតប្រជាជនខ្មែរ ហើយភាគច្រើនខ្មែរតែងនាំគ្នាហៅថា "អ្នកតា"។ តាមការសិក្សារបស់លោក Paul Mus បានពន្យល់ថា ប្រទេសកម្ពុជា ឥណ្ឌាខាងត្បូង និងភូមិភាគបេងហ្គោល មុខតែមានវប្បធម៌តែមួយហៅថា "វប្បធម៌អាស៊ីខ្យល់រដូវ" ដែលផ្អែកលើអ្នកតាជាអ្នកជួយឱ្យដំណាំរបស់គេបានផលល្អ។ លោក George Coedés យល់ថា កាលដើមឡើយខ្មែរប្រហែលជាជនជាតិមួយដែលមានអារ្យធម៌រួចទៅហើយ បន្ទាប់មកទៀតអារ្យធម៌នេះ បានប៉ះទង្គិចគ្នាជាមួយអារ្យធម៌ឥណ្ឌា។

ជាទូទៅ ពិធីឡើងអ្នកតាមានស្ទើរគ្រប់ភូមិនៅក្នុងប្រទេសកម្ពុជា ជាពិសេស គឺនៅទីជនបទ ស្រុកស្រែចម្ការ។ ការប្រារព្ធពិធីឡើងអ្នកតា តែងមានគោលបំណងរួមមួយ គឺបួងសួងសុំនូវសេចក្តីសុខ បណ្តេញឧបទ្រពចង្រៃចេញពីភូមិស្រុក ហើយកិច្ចជាទូទៅមានលក្ខណៈស្រដៀងគ្នា ឬខុសគ្នាខ្លះទៅតាមតំបន់ ឬភូមិស្រុកផ្សេងៗ។ នៅក្នុងអត្ថបទនេះ ខ្ញុំសូមលើកយកពិធីឡើងអ្នកតាមួយដែលខ្ញុំយល់ថាមានលក្ខណៈពិសេសមួយបែបពីតំបន់ដទៃទៀតនៅប្រទេសកម្ពុជា។ ពិធីនេះធ្វើឡើងនៅភូមិចុងព្រៃ ឃុំកំពង់ស្វាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ដែលជាភូមិស្ថិតនៅតាមបណ្តោយផ្លូវបុរាណភ្ជាប់ពីតំបន់ប្រាសាទសំបូរព្រៃគុកឆ្ពោះទៅតំបន់អង្គរ ហើយស្ថិតនៅទិសនិរតីតំបន់ប្រាសាទសំបូរព្រៃគុក ប្រមាណ ១០ គ.ម.។ កិច្ចឡើងអ្នកតានៅភូមិចុងព្រៃ គេប្រារព្ធឡើងនៅខែចេត្រត្រូវនឹងចុងខែមេសា ពោល គឺបន្ទាប់ពីចូលឆ្នាំខ្មែរបានបញ្ចប់។

អត្ថបទដោយ៖ លោក **ម៉ង់ រ៉ាលី**

ក្នុងកិច្ចនេះ យើងសង្កេតឃើញថា នំអន្សមផ្អាវ ឬខ្លះហៅនំក្រៀកង្កែបដើរតួនាទីសំខាន់ណាស់ក្នុងពិធីនេះ ពោល គឺអ្នកភូមិស្ទើរគ្រប់ផ្ទះបាននាំគ្នាវេចនំនេះយកមកថ្វាយអ្នកតាក្នុងថ្ងៃឡើងអ្នកតា។ ក្រៅពីនំអន្សមស្លឹកផ្អាវ អ្វីដែលគួរកត់សម្គាល់ថាប្លែកពីតំបន់ដទៃនោះគឺ កិច្ចនេះគេមានយកក្មេងស្រីៗចំនួន ៧នាក់ មកចូលរួមដែលតំណាងឱ្យនាងក្រមុំទាំងប្រាំពីរ ពោល គឺជាវ័យមួយដែលនៅបរិសុទ្ធមិនមានជាប់ពាក់ព័ន្ធជាមួយអ្នកណា។ ជាពិសេសនោះ អ្វីដែលខ្ញុំចង់លើកឡើងនៅក្នុងអត្ថបទនេះគឺ "អ្នកតាជិះដំរី" ដែលជាកិច្ចមួយប្លែកខ្ញុំពុំធ្លាប់ឃើញមាននៅតំបន់ដទៃទៀត ហើយក៏មិនដឹងថាមានបែបនេះឬអត់ទេ។ អ្នកតាជិះដំរីនេះ គឺធ្វើឡើងនៅក្នុងពេលបញ្ជូន ដែលជាកិច្ចសំខាន់ក្នុងពិធីឡើងអ្នកតា។ ជាទូទៅ នៅតំបន់ផ្សេងៗគេច្រើនបញ្ជូនដោយមានធ្វើពែ សង្សឹក សម្រាប់ដាក់របស់របរផ្សេងៗ រួមទាំងបាយ សម្ល នំចំណី។ល។ ដោយឱ្យក្មេងៗឬមនុស្សចាស់សែងយកទៅទីមិនឆ្ងាយពីខ្ទមអ្នកតា។ ដោយឡែកនៅក្នុងកិច្ចឡើងអ្នកតាភូមិចុងព្រៃនេះវិញ ពេលបញ្ជូន គឺរូបស្នងនៃអ្នកតា (អ្នកតាគង់) ត្រូវជិះលើខ្នងសិស្ស គុនដែលមកចូលរួម ពោល គឺសិស្សគុននោះត្រូវវាធ្វើជាសត្វដំរីឱ្យរូបស្នងអ្នកតាជិះលើខ្នងដែលសិស្សគុននោះត្រូវចងសង្រែកក្រមានៅលើក ដើម្បីធ្វើជាថ្នក់ដាក់នំអន្សមផ្អាវ ដែលគេយកសែនអ្នកតា។ នៅមុនពេលជិះដំរី អ្នកតាបានប្រស់ទឹកនិងឱ្យសិស្សគុនផឹក ស្រាជាមុនសិន។ ក្នុងពេលអ្នកតាជិះដំរី អ្នកភ្លេងត្រូវលេងបទណាដែលរន្ធើនខ្លាំង រីឯអ្នកមកចូលរួមត្រូវស្រែកហ៊ោបន្ទរគ្នា។ ការជិះដំរីដើម្បីបញ្ជូននេះ មិនទៅឆ្ងាយទេ ពោល គឺនៅក្បែររោងកិច្ចពិធីប៉ុណ្ណោះ ហើយពេលដែលទៅដល់រូបស្នងអ្នកតាបានយកនំអន្សមផ្អាវមួយចំនួនបាចទៅក្នុងព្រៃក្នុងន័យបណ្ដេញនូវឧបទ្រពចង្រៃដែលតែងមកយាយីដល់ភូមិស្រុក និងនាំមកវិញនូវសិរីសួស្ដីសុខសុភមង្គល។

ការបញ្ជូនដោយក្នុងទម្រង់លក្ខណៈជិះដំរីរបៀបនេះ ជាទំនៀមដែលកើតឡើងយូរយារណាស់មកហើយ ទំនងដោយសារអ្នកតាគង់ប្រចាំនៅភូមិចុងព្រៃនេះ អ្នកស្រុកយល់ថាជាមេទ័ពដែលតែងជិះដំរីចូលប្រយុទ្ធក្នុងសមរភូមិនៅសម័យបុរាណ ម្យ៉ាងទៀតក៏អាចទាក់ទងនឹងរឿងផ្លូវបុរាណដែរ ដ្បិតរោងអ្នកតាដែលប្រារព្ធពិធីនេះ នៅជាប់តាមដងផ្លូវបុរាណមួយចេញពីតំបន់ប្រាសាទសំបូរព្រៃគុកឆ្ពោះទៅតំបន់អង្គរ។

អត្ថបទដោយ៖ លោក **ម៉ង់ រ៉ាលី**

# អត្ថបទ៖ អ្នកតាជិះដំរី

















អត្ថបទដោយ៖ លោក ម៉ង់ រ៉ាលី